ការិយាល័យកណ្តាល

# សេចក្តីជូនដំណឹង

## ស្តីពី

## កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

ធនាគារ អេស៊ីលីដា ភីអិលស៊ី (“ធនាគារ អេស៊ីលីដា”) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកទាំងអស់ ទទួលជ្រាបថា ដោយអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល **ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៥** ធនាគារ អេស៊ីលីដា នឹងរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ (“កិច្ចប្រជុំ”) តាមរយៈ **អ៊ីម៉ែល** ដែលនឹងប្រព្រឹត្តទៅនៅ **ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥** ចាប់ពីម៉ោង **១៣:០០** ដល់ម៉ោង **១៥:០០ រសៀល** (ម៉ោងនៅភ្នំពេញ) តាមរបៀបវារៈ៖

១. អនុម័តលើការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលសម្រាប់បន្តអាណត្តិថ្មី។

២. អនុម័តការធ្វើវិសោធនកម្មលើលក្ខន្តិកៈធនាគារ អេស៊ីលីដា។

ភាគហ៊ុនិក ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិក**នៅកាលបរិច្ឆេទកំណត់ទុកថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៥** នឹងទទួលបានលិខិតអញ្ជើញ ឯកសារគាំទ្រ សេចក្តីណែនាំការបោះឆ្នោតតាមប្រព័ន្ធ e-Voting លិខិតប្រគល់សិទ្ធិ និង QR Code សម្រាប់ការបោះឆ្នោត ដែលធនាគារ អេស៊ីលីដា នឹងផ្ញើជូនតាមរយៈអ៊ីម៉ែល។ ក្នុងករណីដែលភាគហ៊ុនិកណាម្នាក់ពុំអាចចូលរួម និងបោះឆ្នោតតាមកាលបរិច្ឆេទដូចបានកំណត់ខាងលើ អាចផ្តល់សិទ្ធិប្រទានទៅឱ្យអ្នកតំណាងណាម្នាក់ ដើម្បីចូលរួម និងបោះឆ្នោតជំនួសបាន។ ភាគហ៊ុនិក ឬអ្នកទទួលសិទ្ធិត្រូវផ្ញើលិខិតប្រគល់សិទ្ធិច្បាប់ដើមមកភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្ររបស់ធនាគារ អេស៊ីលីដា យ៉ាងយូរត្រឹម**ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៥**។

ដំណើរការនៃការបោះឆ្នោតមានដូចខាងក្រោម៖

- ធនាគារ អេស៊ីលីដា នឹងផ្ញើ QR Code សម្រាប់ការបោះឆ្នោត ជូនភាគហ៊ុនិកម្នាក់ៗ តាមរយៈអ៊ីម៉ែល ចាប់ពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៥ ម៉ោង ៧:៣០ ព្រឹក រហូតដល់ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ ម៉ោង ១២:០០ ថ្ងៃត្រង់ (ម៉ោងនៅភ្នំពេញ)។
- ភាគហ៊ុនិកម្នាក់ៗត្រូវបោះឆ្នោតនៅ**ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥** ក្នុងចន្លោះពេលណាមួយ ចាប់ពីម៉ោង **១៣:០០** ដល់ម៉ោង **១៥:០០ រសៀល** (ម៉ោងនៅភ្នំពេញ) ដោយបើកកាមេរ៉ាទូរស័ព្ទដៃ ឬ Tablet របស់លោក/អ្នក រួចស្កេន QR Code សម្រាប់ការបោះឆ្នោត (សូមពិនិត្យសេចក្តីណែនាំការបោះឆ្នោតតាមប្រព័ន្ធ e-Voting ដែលនឹងផ្ញើជូនជាមួយ QR Code)។

**បញ្ជាក់៖**

- ភាគហ៊ុនិកដែលមានសិទ្ធិចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ គឺជាភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះផ្លូវការដោយទទួលបានពីបញ្ជីឈ្មោះភាគហ៊ុនិកដែលរៀបចំឡើងនៅ**ថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៥**។
- ភាគហ៊ុនិកដែល **លក់** មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៥** គឺ **នៅតែមានសិទ្ធិ** ចូលរួម និងបោះឆ្នោតក្នុងមហាសន្និបាត។
- ភាគហ៊ុនិកដែល **ទិញ** មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៥** គឺ **មិនមានសិទ្ធិ** ចូលរួម និងបោះឆ្នោតក្នុងមហាសន្និបាតឡើយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិកទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមកិច្ចប្រជុំនេះ តាមរយៈអ៊ីម៉ែលតាមកាលបរិច្ឆេទដូចបានកំណត់ខាងលើដោយសេចក្តីអនុគ្រោះ។ ប្រសិនបើលោក/អ្នកមានតម្រូវការ ឬសំណួរផ្សេងៗ សូមទំនាក់ទំនងមកផ្នែកប្រតិបត្តិការបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ (ភ្នាក់ងារ RTP) របស់ធនាគារ អេស៊ីលីដា ដូចខាងក្រោម៖

- **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ**
  - ទូរស័ព្ទ: (៨៥៥) ៧០ ៥០០ ៣៧៧
  - អ៊ីម៉ែល: samreth.vannybopharath@acledabank.com.kh
- **កញ្ញា ចាន់ ទេពកញ្ញា**
  - ទូរស័ព្ទ: (៨៥៥) ១៦ ២៩៥ ៤៣២
  - អ៊ីម៉ែល: op.rtp@acledabank.com.kh
- **លោក កែន រិទ្ធពុទ្ធា**
  - ទូរស័ព្ទ: (៨៥៥) ១៥ ៨០០ ៦៦៣
  - អ៊ីម៉ែល: ken.rithputhea@acledabank.com.kh

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិកទាំងអស់មេត្តាជ្រាបជាព័ត៌មាន៕

ថ្ងៃអង្គារ ៨កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៥

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**